(២៥)

# សារាចរណែនាំស្តីពី

# លិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ

លេខ: ០០៦ សហវ

ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ១៧៤០
ថ្ងៃទី ១៤-៦-១៦
បញ្ជូន.........

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ.

នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ
ទទួលថ្ងៃទី ០៧ ខែ ០៦
លេខ: ១៥៦
ម៉ោង ........

រាជធានីភ្នំពេញ, ថ្ងៃទី១១ខែមេសាឆ្នាំ២០១៦

## សារាចរណែនាំ

### ស្តីពី

### លិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកា ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ

សារាចរណែនាំនេះមានគោលបំណងបង្កើនប្រសិទ្ធភាពស័ក្តិសិទ្ធភាព និងធានាបាននូវសង្គតិភាព នៃការគ្រប់គ្រង និងការត្រួតពិនិត្យការទូទាត់ចំណាយថវិកា ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ឱ្យមានភាពច្បាស់លាស់ និងត្រឹមត្រូវស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

បន្ថែមពីលើប្រកាសលេខ៥៨០ សហវ.ប្រក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពី "ការដាក់ឱ្យប្រើប្រាស់សៀវភៅគោលការណ៍ណែនាំស្តីពីនីតិវិធីចំណាយថវិកា និងបែបបទត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់ថវិកាចរន្តថ្នាក់ជាតិ" ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ដូចខាងក្រោម៖

១. លិខិតរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីសំណើសុំទូទាត់ទំនិញ សំណង់ ឬ សេវា

២. អាណត្តិបើកប្រាក់, ដីការអមបញ្ចេញអាណត្តិបើកប្រាក់, ដីការអមលិខិតយុត្តិការ

៣. សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ

៤. លិខិតផ្តល់ធានាចំណាយចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធពេលស្នើសុំគោលការណ៍ធានាចំណាយ រួមទាំងគម្រោងចំណាយ/បញ្ជីប៉ាន់តម្លៃ (ច្បាប់ដើម)

៥. កំណត់ហេតុស្ទង់តម្លៃ/ចរចារថ្លៃ/ពិគ្រោះថ្លៃ/ដេញថ្លៃ (ច្បាប់ដើម)
(សម្រាប់អាណត្តិបើកប្រាក់ទាំងឡាយដែលអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈក្រោមសិទ្ធិសម្រេច សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ)

៦. លិខិតធានាប្រាក់កក់ធានាការអនុវត្ត (ច្បាប់ដើម)

៧. កិច្ចសន្យាលទ្ធកម្មដែលមានពន្ធប្រថាប់ត្រា (ច្បាប់ដើម)

៨. កំណត់ហេតុវាយតម្លៃលទ្ធផលការងារ ឬ កំណត់ហេតុប្រគល់ ទទួល (ច្បាប់ដើម)

៩. ប័ណ្ណបញ្ចេញបញ្ចូលឃ្លាំង (ក្នុងករណីការផ្គត់ផ្គង់ទំនិញ) (ច្បាប់ដើម)

១០. ច្បាប់អាជីវកម្ម និងប័ណ្ណប៉ាតង់ (ប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់)

(ច្បាបចម្លងមានការបញ្ជាក់ទទួលស្គាល់)

គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការអនុវត្តខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

<u>ចម្លងជូន៖</u>

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*